ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ ០១៩ រ.បក ...អ.ជ.ប.គ.ញ.

ថ្ងៃអង្គារ ១កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែមករា និងលើកទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦

(ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៦)

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន(អ.ជ.ប.គ.ញ.) ជាសេនាធិការឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការសម្របសម្រួល ប្រមូលផ្តុំដឹកនាំ និងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ស្របតាមទិសដៅការងារដែលបានដាក់ចេញពីខែធ្នូឆ្នាំ២០២៥កន្លងមក ក៏ដូចជាយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដាក់ស្តែង ក្នុងខែមករា ឆ្នាំ២០២៦នេះ យើងបានបូកសរុបនិងទទួលបាននូវលទ្ធផល ដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែមករា ឆ្នាំ២០២៦នេះ បទល្មើសគ្រឿងញៀន នៅតែមានស្ថានភាពប្រែប្រួលស្មុគស្មាញ ដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀនតែងតែផ្លាស់ប្តូរកលល្បិច វិធីសាស្ត្រ និងប្រើប្រាស់បច្ចេកវិទ្យានៃការធ្វើសកម្មភាពចរាចរ ដឹកជញ្ជូន ជួញដូរនិងលួចលាក់កែច្នៃគ្រឿងញៀនគួរឱ្យកត់សម្គាល់ ក្នុងនោះបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើង ត្រូវបានសមត្ថកិច្ចបង្ក្រាប រួមមានបទល្មើសកែច្នៃនូវសារធាតុញៀន ១ករណី នៅរាជធានីភ្នំពេញ ចាប់យកគ្រឿងញៀន **៤៧៧គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ៣នាក់។ បទល្មើសដឹកជញ្ជូន ជួញដូរគ្រឿងញៀនឆ្លងដែនតាមបញ្ញើប្រៃសណីយ៍(ពីកម្ពុជាទៅអូស្ត្រាលី) ១ករណី នៅរាជធានីភ្នំពេញ ចាប់យកគ្រឿងញៀន **១គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២នាក់។ ដោយឡែកបទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរនូវគ្រឿងញៀនក្នុងផ្ទៃប្រទេស(មានប្រភពមកពីឡាវ) ៨ករណី នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រះសីហនុ និងខេត្តសៀមរាប ចាប់យកគ្រឿងញៀន **៣០គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ១៤នាក់។

**ការកត់សម្គាល់** ក្រៅពីស្ថានភាពនៃបទល្មើសគ្រឿងញៀនខាងលើ ក្នុងក្របខ័ណ្ឌនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ បានបង្ហាញឱ្យឃើញថា ការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន បានធ្វើសកម្មភាពជាប្រចាំ ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនបានអនុវត្តកាន់តែសកម្មនិងមាន៖



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

ប្រសិទ្ធភាពជាងមុន ការអនុវត្តវិធានការរដ្ឋបាលនិងវិធានការច្បាប់នៅតាមគោលដៅក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន ដោយធ្វើកិច្ចសន្យាធានាមិនឱ្យមានការជួញដូរនិងប្រើប្រាស់គ្រឿងញៀនក្នុងទីតាំង អាជីវកម្មរបស់ខ្លួនបានជាច្រើនកន្លែង និងការពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធទៅវិញទៅមកបានជាបន្តបន្ទាប់ផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ ទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

បានសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមប្រព័ន្ធផ្សព្វផ្សាយ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **៤២.១២៦ដង** (ខែធ្នូឆ្នាំ២០២៥ មាន ៣៤.៦៩៨ដង) ច្រើនជាង ៧.៤២៨ដង កើនឡើង **២១,៤%**
- ចូលរួមជាវាគ្មិនកិត្តិយសនៅក្នុងកម្មវិធីសន្ទនាមតិ «ជំហានដំបូង» ក្រោមប្រធានបទស្តីពី **«ការប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ពិតជាអស់កង្វល់ក្នុងការរាយការណ៍ពីបញ្ហាគ្រឿងញៀន»** នៅអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា រាជធានីភ្នំពេញ
- ផ្សព្វផ្សាយអប់រំតាមរយៈឃ្លីបវីដេអូខ្លីៗ តាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និងកម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- សហការសម្របសម្រួលជាមួយស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ទំនាក់ទំនង សម្របសម្រួលជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងធម្មការ និងសាសនា ដើម្បីផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន
- ជួបតំណាងក្រសួង ស្ថាប័ន ដៃគូ និងមហាជន ដើម្បីបញ្ជ្រាបសារអប់រំ ស្តីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងបង្កើនការចូលរួមផលិតមាតិកាសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងសង្គម
- បញ្ជ្រាបសារអប់រំ ស្តីពីបញ្ហាគ្រឿងញៀន ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនទៅក្នុងកម្មវិធីរបស់ក្រុមហ៊ុនហង្សមាសវីដេអូ បទចំរៀងក្រុមហ៊ុនហ្គាឡាក់ស៊ីឡេងណាវ៉ាត់ត្រា និងកម្មវិធីប្រដាល់ដែលរៀបចំដោយសហព័ន្ធកីឡាប្រដាក់គុនខ្មែរ នៅតាមបណ្តាទូរទស្សន៍នានា និងកម្មវិធីប្រកួតកីឡាអេឡិចត្រូនិក។

#### ១.២. ការងារផ្សព្វផ្សាយអប់រំតាមសហគមន៍

បានសហការសម្របសម្រួល និងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- ចូលរួមជាវាគ្មិនក្នុងពិធីផ្សព្វផ្សាយ អប់រំ ស្តីពីការយល់ដឹងពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ផលប៉ះពាល់នៃបារីអេឡិចត្រូនិក និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ជូនដល់សិស្សានុសិស្សថ្នាក់មធ្យមសិក្សានៃសាលារៀនអន្តរទ្វីបអាម៉េរិកាំង នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

- ជួបប្រជុំជាមួយយោធាចារ្យនៃសាកលវិទ្យាល័យការពារជាតិ ពិនិត្យនិងកែសម្រួលបញ្ចប់លើសេចក្តីព្រាងឯកសារគោល ស្តីពីគ្រឿងញៀន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

- រៀបចំកិច្ចប្រជុំត្រួតពិនិត្យលើវឌ្ឍនភាព និងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug តាមប្រព័ន្ធអនឡាញ

- ចែករំលែកចំណេះដឹងពាក់ព័ន្ធការចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រឆាំង ការជួញដូរគ្រឿងញៀនខុសច្បាប់នៅប្រទេសឥណ្ឌាកន្លងមក ដល់មន្ត្រីនៃនាយកដ្ឋានផ្សព្វផ្សាយ អប់រំ និងទំនាក់ទំនងសាធារណៈ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

- ជួបក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងធម្មការនិងសាសនា ដើម្បីពិភាក្សាការងាររៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ឆ្នាំ២០២៦

- រៀបចំឯកសារចុះសហគមន៍បណ្តាញគ្រីស្ទបរិស័ទ នៃក្រុមប្រឹក្សាបណ្តាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជាខេត្តព្រះសីហនុ លើការងារអនុវត្តកម្មវិធីគ្រួសាររឹងមាំ( Strong Family )

- បញ្ជ្រាបខ្លឹមសារអប់រំ ស្តីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ទៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ខែមករា ឆ្នាំ២០២៦

- សម្របសម្រួលជាមួយគណៈកម្មាធិការសម្របសម្រួល ជំរុញ អនុវត្ត និងត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ ដើម្បីជំរុញឱ្យរាជធានី ខេត្ត រៀបចំសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងកម្មវិធីទូរស័ព្ទដៃ NoDrug

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនបានចំនួន **១៦.៧៣៩លើក** (ខែធ្នូឆ្នាំ២០២៥ មាន ១៦.១៣៩លើក) ច្រើនជាង ៦០០លើក កើនឡើង **៣,៧%** ដោយគ្របដណ្តប់លើអ្នកមកទទួលយកសារ **១.០០១.៣០៨នាក់** ស្រី ៥៧០.៤៩០នាក់ (ខែធ្នូឆ្នាំ២០២៥ មាន ១០០៨.៥៥២នាក់) តិចជាង ៧.២៤៤នាក់ ថយចុះ **០,៧%**

- ជំរុញ បំផុស ផ្សព្វផ្សាយ ការទាញយកនិងប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃ NoDrug រហូតមកដល់ពេលបច្ចុប្បន្ននេះមានចំនួន **៧៩.៩៩៨នាក់** (ខែធ្នូឆ្នាំ២០២៥ មាន ៦៧.៣៨៩នាក់) ច្រើនជាង ១២.៦០៩នាក់ កើនឡើង **១៨,៧%**។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាព្យាបាល ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

## ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

សម្របសម្រួល និងអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

– ក្រសួងសុខាភិបាល បានបន្តផ្តល់សេវាព្យាបាលឱសថជំនួសដោយមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន បានចំនួន ៥៤នាក់ ស្រី ៨នាក់ ដែលមានទីតាំងនៅមន្ទីរបង្អែកច្បារអំពៅ និងមន្ទីរពេទ្យមិត្តភាពកម្ពុជា សូវៀត។

– អង្គការដៃគូបានអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម បានចំនួន **៧០៨នាក់** ស្រី ១២៦នាក់ (ខែធ្នូឆ្នាំ២០២៥ មាន ៦៩៧នាក់) ច្រើនជាង ១១នាក់ កើនឡើង **១,៦%**។

## ២.២.ការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

សម្របសម្រួល និងពង្រឹងសមត្ថភាពការងារព្យាបាល ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

– តាមរយៈការព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន បានចំនួន ២.២៣៨នាក់ ស្រី ៧៩នាក់ រួមមានមន្ទីរពេទ្យបង្អែកចំនួន ៤៧៣នាក់ ស្រី ២៤នាក់ និងមណ្ឌលសុខភាពចំនួន ១៩នាក់ ស្រី ២នាក់

– ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន បានចំនួន ១២.១៨៨នាក់ ក្នុងនោះមាន អ្នកកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលចំនួន ៨.៥៥៩នាក់ ស្រី ៤៧០នាក់ អ្នកចូលថ្មីចំនួន ១.៧៣៦នាក់ ស្រី ១០៦នាក់ និងបានធ្វើសមាហរណកម្មចំនួន ១.៨៩៣នាក់ ស្រី ៨៥នាក់

– រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងតួនាទី និងភាររបស់នាយកដ្ឋានស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.

– រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស ដើម្បីពិនិត្យវឌ្ឍនភាពការងាររៀបចំថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.។

# ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ដើម្បីពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់ ឈានទៅបំផ្លាញបណ្តាញអង្គការចាត់តាំងឧក្រិដ្ឋជនគ្រឿងញៀន និងការទប់ស្កាត់ការចរាចរគ្រឿងញៀនគ្រប់ប្រភេទឆ្លងកាត់តំបន់ព្រំដែន បានបន្តសហការសម្របសម្រួលជាមួយស្ថាប័នអនុវត្តច្បាប់ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

## ៣.១.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បានសហការសម្របសម្រួលក្នុងការរៀបចំ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងកម្មវិធីនានា ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

– រៀបចំកិច្ចប្រជុំនៃក្រុមការងារប្រតិបត្តិការមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (SMCC) សម្រាប់បណ្តាប្រទេសជាសមាជិកទាំង៦ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ តាមប្រព័ន្ធអនឡាញ

- ចូលរួមកិច្ចប្រជុំលើកទី១០ នៃក្រុមការងារបង្ក្រាបគ្រឿងញៀនតាមកំពង់ផែអាស៊ាន (10th ASITF) ដែលរៀបចំដោយគណៈកម្មាធិការកណ្តាលត្រួតពិនិត្យគ្រឿងញៀនមីយ៉ាន់ម៉ា(CCDAC) តាមប្រព័ន្ធអនឡាញ

- ចូលរួមសិក្ខាសាលាអាស៊ាន-ចិន ស្តីពីការពិនិត្យទីកន្លែងបង្ក្រាបគ្រឿងញៀន ដែលរៀបចំដោយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន(NNCC) នៅខេត្តយូណាន ប្រទេសចិន

- ចូលរួមសន្និសីទ ស្តីពីប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នៅតំបន់អាស៊ីប៉ាស៊ីហ្វិក លើកទី២៨ (ADEC-28) ដែលរៀបចំដោយទីភ្នាក់ងារនគរបាលប្រទេសជប៉ុន នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

- ទទួលការរាយការណ៍ពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ចំនួន **៧០១ករណី** (ខែធ្នូឆ្នាំ២០២៥ មាន ៥៤៨ករណី) ច្រើនជាង ១៥៣ករណី កើនឡើង **២៨%** ក្នុងនោះ ដោះស្រាយរួច ៥៣៧ករណី កំពុងដោះស្រាយ ១៣៤ករណី សាកល្បង ៧ករណី ករណីជដែល ១៧ករណី និងផ្សេងៗ ៦ករណី

- បញ្ចូលទិន្នន័យព័ត៌មានពាក់ព័ន្ធករណីបង្ក្រាបបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើងទៅក្នុងប្រព័ន្ធទិន្នន័យរបស់គម្រោងសុវត្ថិភាពទន្លេមេគង្គ(Safe Mekong Coordination Centre) បានចំនួន ១៤ករណី ជនសង្ស័យ ចំនួន ៦៦នាក់ គ្រឿងញៀនចំនួន ៨១គីឡូក្រាម។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **៨៦៥ករណី**(ខែធ្នូឆ្នាំ២០២៥ មាន ៩៤៧ករណី) តិចជាង ៨២ករណី ថយចុះ **៨%**។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២.១០៨នាក់** ស្រី ១៣០នាក់(ខែធ្នូឆ្នាំ២០២៥ មាន ២.៥៥២នាក់) តិចជាង ៤៤៤នាក់ ថយចុះ **១៧%** ក្នុងនោះ ជនជាតិខ្មែរ ២.០១៤នាក់ (ស្រី ១២៣នាក់) និងជនជាតិបរទេស ៩៤នាក់(ស្រី ៧នាក់) រួមមាន វៀតណាម ២៥នាក់(ស្រី ៧នាក់) កូរ៉េខាងត្បូង ១នាក់ អាម៉េរិក ១នាក់ ឥណ្ឌូនេស៊ី ៨នាក់ ឥណ្ឌា ៥នាក់ បារាំង ១នាក់ នេប៉ាល់ ២នាក់ បង់ក្លាដេស ១នាក់ និងចិន ៥០នាក់ ក្នុងនោះចិនតៃវ៉ាន់ ៨នាក់

- **ចាប់យកគ្រឿងញៀន** ចំនួន **៥៤១គ.ក្រ ៩៥៤,២៦ក្រាម**(ខែធ្នូឆ្នាំ២០២៥ ១០៥គ.ក្រ ៧,៣៤ក្រាម) ច្រើនជាង ៤៣៦គ.ក្រ ៩៤៦,៩២ក្រាម

- ចាប់យកសារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ ចំនួន **៦៧៤,៩៦គីឡូក្រាម**

- ចាប់យកកញ្ឆាស្ងួត ចំនួន **៦គីឡូក្រាម ៤៣២ក្រាម**

- **សម្ភារចាប់យក**ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន រថយន្ត ១៨គ្រឿង ម៉ូតូ ២០២គ្រឿង ទូរស័ព្ទ ៩០៣គ្រឿង ជញ្ជីង ៧២គ្រឿង អាវុធខ្លី ៧ដើម អាវុធវែង ១ដើម និងរូបិយវត្ថុជាតិ អន្តរជាតិ(២០៤.៣០០រៀល និង២០០ដុល្លារ)

- **អនុវត្តដីកា** បានចំនួន ៥៨ដីកា ចាប់ខ្លួនជនសង្ស័យចំនួន ៤៩នាក់

- **ក្នុងចំនួនករណីគ្រឿងញៀនខាងលើ៖**

  - ករណីបង្ក្រាបដោយ**សមត្ថកិច្ចនគរបាលចំនួន ៧៧៥ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ១.៩១៣នាក់ (ស្រី ១០៩នាក់)

  - ករណីបង្ក្រាបដោយ**សមត្ថកិច្ចកងរាជអាវុធហត្ថចំនួន ៩០ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ១៩៥នាក់ (ស្រី ២១នាក់)

- **ការកត់សម្គាល់លើបទល្មើសគ្រឿងញៀន៖**
  - ករណីធំៗ ចាប់ពី **១គីឡូក្រាមឡើង** មាន **១០ករណី** (ចោទពីបទសម្អាតប្រាក់**៥ ករណី**) ឃាត់ខ្លួនជនសង្ស័យបាន **១៩នាក់(ស្រី ៤នាក់)** ក្នុងនោះ ខ្មែរ ១២នាក់(ស្រី ៣នាក់) វៀតណាម ៣នាក់ (ស្រី ១នាក់) ចិន ៣នាក់ និងកូរ៉េខាងត្បូង ១នាក់ ចាប់យកគ្រឿងញៀន **៥០៩គីឡូក្រាម ៥៧៩,៨៥ក្រាម** សារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ **៦៦៤គីឡូក្រាម ៩៦៩,៨៥ក្រាម**
  - ករណីមធ្យម ចាប់ពី ១០០ក្រាមឡើង មាន ១០២ករណី ឃាត់ខ្លួនជនសង្ស័យ ២៨៧នាក់
  - ករណីតូចតាច ចាប់ពី ៩៩ក្រាមចុះក្រោម មាន ៧៥៣ករណី ឃាត់ខ្លួនជនសង្ស័យ ១.៧៩៩នាក់។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **៧០៥លើក** ក្នុងនោះ ចុះអប់រំម្ចាស់ទីតាំងអាជីវកម្មបាន ៦០៤លើក រួមមាន **៥គោលដៅ** (សណ្ឋាគារ ១០លើក ផ្ទះសំណាក់ ៧៩លើក ផ្ទះជួល ៤៩២លើក KTV ២០លើក និងក្លឹប ៣លើក) និងអញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំបាន ១០១លើក អ្នកចូលរួមចំនួន ៣.៩០៣នាក់(ស្រី ១.៧៧៥នាក់)។ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចុះធ្វើតេស្តរហ័សរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **៧០លើក** លើមុខសញ្ញាចំនួន **៣២២នាក់(ស្រី ៣២នាក់)** រកឃើញវិជ្ជមានសារធាតុញៀន **៨៧នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។

### ៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន

– បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ចំនួន **៩០០សំណាក** ស្មើនឹង **៥៤៦ករណី** ក្នុងនោះ សំណាកវិជ្ជមាន ៨៣៥សំណាក ស្មើនឹង ៩២,៧៨% និងសំណាកអវិជ្ជមាន ៦៥សំណាក ស្មើនឹង ៧,២២%

– បានផលិតតេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្គីតេស្ត (Marquis test) បានចំនួន ២.៦៦០តេស្ត

– បានផ្តល់តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្គី ចំនួន ១.០០០តេស្ត និងប្រភេទកេតាមីន ចំនួន ២.៥០០តេស្ត ជូនដល់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

ជាមួយគ្នានេះ តាមរយៈនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បានផ្តល់តេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ មានដូចជា៖

- ប្រភេទអ៊ិចស្តាស៊ី កេតាមីន និងប្រភេទមេតំហ្វេតាមីន ចំនួន ១.០៥២តេស្ត ជូនដល់ស្នងការដ្ឋាននគរបាលខេត្តមណ្ឌលគិរី
- ប្រភេទមេតំហ្វេតាមីន ចំនួន ៥០តេស្ត ជូនដល់ក្រុមអង្កេតបទល្មើសឆ្លងដែន(TCT)។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

បានអនុវត្តសកម្មភាពការងារគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរពីជំនួញស្របច្បាប់ យកទៅកែច្នៃគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលដូចខាងក្រោម៖

– ជំរុញក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឱ្យបន្តណែនាំដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំស្ថិតក្រោមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ណែនាំ

– ជំរុញក្រសួង ស្ថាប័នជំនាញ បន្តចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ឱ្យបានជាប្រចាំ

– ក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ក្នុងការនាំចូលនូវវត្ថុធាតុដើមផលិតឱសថ និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន **២.៩៤២តោន ៣៣០គ.ក្រ** និង**១៦៨ លីត្រ** (ខែធ្នូឆ្នាំ២០២៥ មាន **៧.៥១៤តោន ៨៧៤គ.ក្រ**) តិចជាង ៤.៥៧២តោន ៥៤៤គ.ក្រ ថយចុះ **៦០,៨%**។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ដើម្បីពង្រឹង និងពង្រីកប្រសិទ្ធភាពក្នុងការសម្របសម្រួលអនុវត្តយន្តការនៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងក្របខ័ណ្ឌទ្វេភាគីជាមួយបណ្តាប្រទេសជាប់ព្រំដែន ជាលទ្ធផលមានដូចខាងក្រោម៖

– បន្តពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន (BLO) រវាងកម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម ជាប់ជាប្រចាំ

– បន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ សគ្គានគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

ដើម្បីធានា ឱ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានា និងសម្របសម្រួលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ និងជាមួយការិយាល័យអង្គការ UNODC ជាលទ្ធផលដូចខាងក្រោម៖

– ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំមន្ត្រីទំនាក់ទំនង នៃប្រទេសហត្ថលេខីលើអនុស្សរណៈយោគយល់គ្នាស្តីពីការត្រួតពិនិត្យគ្រឿងញៀនក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមប្រព័ន្ធអនឡាញ

– ផ្តល់របាយការណ៍ ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-វៀតណាម-ឡាវ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

ដើម្បីបន្តពង្រឹងប្រសិទ្ធភាព និងធ្វើជាសេនាធិការក្នុងការចាត់តាំងដឹកនាំ អនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលក្ខណពហុវិស័យនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– អនុវត្តនូវបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងមន្ត្រីជាប់កិច្ចសន្យា មកដល់បច្ចុប្បន្ន**ចំនួន ១៣៩.៤១៣នាក់** ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀនចំនួន ១០៧នាក់ បណ្តេញចេញពីក្របខ័ណ្ឌចំនួន ១០៣នាក់ ស្ថិតនៅការតាមដាន ៣នាក់ និងកំពុងរៀបចំនីតិវិធីចំនួន ១នាក់

– ជំរុញក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត បន្តអនុវត្តសេចក្តីណែនាំ ស្តីពីដំណើរការធ្វើតេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រ

– ជំរុញការអនុវត្តផែនការសកម្មភាព ស្តីពីការចាត់តាំងអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់

– ជំរុញការអនុវត្តនូវបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

– ប្រជុំត្រួតពិនិត្យលើការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រចាំខែធ្នូ ឆ្នាំ២០២៥ និងលើកទិសដៅការងារខែមករា ឆ្នាំ២០២៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំពិនិត្យ ពិភាក្សា និងផ្តល់ធាតុចូលលើសទ្ធានុក្រមបច្ចេកសព្ទពាក់ព័ន្ធគ្រឿងញៀន នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពការងាររបស់អនុគណៈកម្មការពិធីការ និងផ្គត់ផ្គង់ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ប្រជុំពិនិត្យ ពិភាក្សាលើការងារត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ក្រោមសហប្រធានឯកឧត្តម **ពៅ សាលីដេត** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជានាយកខុទ្ទកាល័យ ឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធានអ.ជ.ប.គ.ញ. និងឯកឧត្តម នាយឧត្តមសេនីយ៍ **មាស វិរិទ្ធ** អគ្គលេខាធិការនៃ អ.ជ.ប.គ.ញ. នៅសាលប្រជុំអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– បន្តសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជំរុញឱ្យមានប្រសិទ្ធភាពការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមបណ្តាភូមិសាស្ត្រស្មុគស្មាញ។

**ក្រៅពីលទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខាងលើ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រីចូលរួមដូចខាងក្រោម៖**

– ក្នុងពិធីបិទសន្និបាតបូកសរុបការងារសុខាភិបាលលើកទី៤៥ និងលើកទិសដៅការងារបន្តក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលរៀបចំដោយក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា

– ក្នុងពិធីប្រកាសសមាសភាពថ្នាក់ដឹកនាំ នៃគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម(គ.ជ.ប.ទ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំរាយការណ៍ ស្ដីពីការរៀបចំខ្លឹមសារនិងឯកសារពាក់ព័ន្ធ នៃការប្រព្រឹត្តទៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំគណៈកម្មការរៀបចំសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងមហាផ្ទៃ និងឆ្លងរបាយការណ៍ ស្ដីពីលទ្ធផលនៃចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព» ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ នៅទីស្ដីការក្រសួងមហាផ្ទៃ

– ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ធនធានមនុស្ស សវនកម្មផ្ទៃក្នុង អគ្គសញ្ញាណកម្ម អគ្គនាយកដ្ឋានរដ្ឋបាល និងក្រុមប្រឹក្សានីតិកម្ម នៅទីស្ដីការក្រសួងមហាផ្ទៃ

– ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលរាជធានី ខេត្ត នៅសាលប្រជុំសាលារាជធានី ខេត្តនីមួយៗ

– កិច្ចប្រជុំលេខាធិការដ្ឋានក្រុមការងារទទួលបន្ទុកធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងដំឡើងមន្ត្រីជាក់ស្ដែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព ការរៀបចំសៀវភៅសទ្ទានុក្រមបច្ចេកសព្ទក្នុងវិស័យសន្តិសុខសង្គមនៃក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ

– ក្នុងពិធីប្រកាសចូលកាន់មុខតំណែងប្រធាននាយកដ្ឋានគាំពារអ្នកញៀនគ្រឿងញៀន នៃអគ្គនាយកដ្ឋានស្ដារសម្បទា នៅទីស្ដីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

– កិច្ចប្រជុំពិនិត្យ និងផ្ដល់ធាតុចូលលើកម្រងសំណួរនៃរបាយការណ៍ ស្ដីពីការរកឃើញទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០២៥ របស់ក្រសួងការងារសហរដ្ឋអាម៉េរិក នៅទីស្ដីការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

– កិច្ចប្រជុំពិនិត្យលើសេចក្ដីព្រាងរបាយការណ៍បូកសរុបលទ្ធផលការងារយេនឌ័រប្រចាំឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២៥ នៅទីស្ដីការក្រសួងមហាផ្ទៃ

– កិច្ចប្រជុំពិភាក្សាត្រៀមរៀបចំកម្មវិធីជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកសម្ភារៈគ្រឿងឧបភោគផ្ដល់ជូនដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក្នុងស្រុកសំពៅលូន និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង នៅទីស្ដីការក្រសួងមហាផ្ទៃ។

## III. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែកុម្ភៈ ឆ្នាំ២០២៦

ដើម្បីបន្តអនុវត្តឱ្យមានប្រសិទ្ធភាពលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារសម្រាប់ខែកុម្ភៈ ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពង្រឹងការងារផ្សព្វផ្សាយអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ សិល្បៈភាពយន្ត លើស្លាកសញ្ញាផលិតផលក្នុងស្រុក និងតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀត។

**១.២.** បន្តសម្របសម្រួលនិងជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៣.** បន្តសហការនិងជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។

**១.៤.** បន្តពង្រឹងការបញ្ជ្រាបខ្លឹមសារអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈសកម្មភាពផ្សេងៗរបស់ដៃគូ។

**១.៥.** បន្តសហការនិងសម្របសម្រួលដើម្បីត្រៀមរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហព័ន្ធកីឡាបាល់ទាត់ និងសហភាពសហព័ន្ធយុវជនកម្ពុជា។

**១.៦.** បន្តចលនា កៀរគរឱ្យមានការចូលរួមផុលផុសនិងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គមលើការងារផ្សព្វផ្សាយអប់រំ ស្ដីពីបញ្ហាគ្រឿងញៀន។

**១.៧.** ត្រៀមជួបតំណាងក្រសួង ស្ថាប័ន ដៃគូ និងមហាជន ដើម្បីបញ្ជ្រាបសារអប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងបង្កើនការចូលរួមផលិតមាតិកាសម្រាប់ផ្សព្វផ្សាយតាមប្រព័ន្ធទំនាក់ទំនងសង្គម។

**១.៨.** ត្រៀមចូលរួមជាមួយក្រសួងមហាផ្ទៃ រៀបចំតាំងពិព័រណ៍ ស្ដីពីគ្រឿងញៀន ក្រោមប្រធានបទ «ការពន្លឿនអនាគតឌីជីថល អភិបាលកិច្ច កំណើន និងភាពជាដៃគូសកល»។

**១.៩.** ត្រៀមចុះសហគមន៍បណ្ដាញគ្រីស្ទបរិស័ទ នៃក្រុមប្រឹក្សាបណ្ដាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជាខេត្តព្រះសីហនុ លើការងារអនុវត្តកម្មវិធីគ្រួសាររឹងមាំ(Strong Family)។

**១.១០.** ត្រៀមជួបក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីពិភាក្សាការងាររៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនសម្រាប់ឆ្នាំ២០២៦។

**១.១១.** ត្រៀមដឹកនាំកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ដើម្បីបញ្ចប់សេចក្តីព្រាងលើឯកសារគោល ស្ដីពីការយល់ដឹងអំពីគ្រឿងញៀន។

**១.១២.** ត្រៀមជួបដៃគូ MOU ដើម្បីពិភាក្សាការងារនិងថ្លែងអំណរគុណដល់ការចូលរួមក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**១.១៣.** ត្រៀមចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយ ស្ដីពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន និងបារីអេឡិចត្រូនិក នៅសាលាបញ្ញាសាស្ត្រអន្តរជាតិ។

**១.១៤.** ត្រៀមចូលរួមសិក្ខាសាលាផ្សព្វផ្សាយ អប់រំ ស្ដីពីផលប៉ះពាល់ដល់សុខភាពបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀន និងបារីអេឡិចត្រូនិក នៅតាមគ្រឹះស្ថានសិក្សាក្នុងខេត្តកណ្ដាល និងខេត្តកំពង់ចាម។

### ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្ដារនីតិសម្បទា និងសមាហរណកម្ម

**២.១.** បន្តសហការ សម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ផ្ដល់ទិន្នន័យអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន ឱ្យបានទៀតទាត់។

**២.២.** បន្តជំរុញមជ្ឈមណ្ឌលព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន ឱ្យរៀបចំមាតិកាសម្រាប់ដាក់លើកម្មវិធីទូរស័ព្ទដៃ NoDrug។

**២.៣.** ត្រៀមជូនដំណឹងដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ក្នុងការពង្រឹង ឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍នៅតាមឃុំ សង្កាត់ ដើម្បីជំរុញអ្នកញៀនគ្រឿងញៀនទៅទទួលការព្យាបាលតាមសហគមន៍ និងការថែទាំបន្ត។

**២.៤.** ត្រៀមចុះពិនិត្យទីតាំងការអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម។

**២.៥.** ត្រៀមសហការ សម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដើម្បីផ្សព្វផ្សាយ និងអនុវត្តនិយាមនីតិវិធីប្រតិបត្តិ(SOP) សម្រាប់មជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.៦.** ត្រៀមសហការ និងសម្របសម្រួលជាមួយគណៈអភិបាលខេត្តស្វាយរៀង ដើម្បីចុះពិនិត្យទីតាំងសាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

**២.៧.** ត្រៀមសម្របសម្រួលជាមួយតំណាងក្រសួងសន្តិសុខសាធារណៈអមស្ថានអគ្គរដ្ឋទូតនៃសាធារណៈសង្គមនិយមវៀតណាមប្រចាំនៅប្រទេសកម្ពុជា ពាក់ព័ន្ធនឹងការស្នើសុំជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅខេត្តស្វាយរៀង។

**២.៨.** ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលការប្រើប្រាស់ថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋ និងឯកជន។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ជាអាទិភាពនូវការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែន តាមផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍ ពិសេសនៅតំបន់ព្រំដែន កម្ពុជា-ឡាវ និងកម្ពុជា-វៀតណាម។

**៣.២.** ត្រៀមផ្សព្វផ្សាយខ្លឹមសារសេចក្តីសម្រេច ស្តីពីការរៀបចំនឹងប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៣.៣.** ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការទប់ស្កាត់ និងបង្ក្រាបការចរាចរគ្រឿងញៀនតាមប្រព័ន្ធកុំព្យូទ័រ(CBT) ដល់មន្ត្រីអនុវត្តច្បាប់។

**៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន៖**

– បន្តពិនិត្យលទ្ធភាពដើម្បីផ្គត់ផ្គង់ឧបករណ៍ធ្វើតេស្តគ្រឿងញៀន និងឧបករណ៍ធ្វើតេស្តរហ័សរកសារធាតុញៀនតាមទឹកមូត្រដល់ក្រសួង ស្ថាប័នអនុវត្តច្បាប់ ឱ្យបានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់

– ត្រៀមពិនិត្យនិងធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន និងផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្គីតេស្ត (Marquis test) និងកេតាមីន (Ketamine test)

– ត្រៀមរៀបចំវេចខ្ចប់ ដឹកជញ្ជូនសារធាតុគីមី និងសារធាតុគីមីផ្សំដែលស្ថាប័នតុលាសម្រេចរឹបអូស ចេញពីកំពង់ផែស្វយ័តភ្នំពេញ រាជធានីភ្នំពេញ និងខេត្តកណ្តាល ទៅរក្សាទុកនៅឃ្លាំងសុវត្ថិភាព នៅខេត្តកំពង់ស្ពឺ ដើម្បីរង់ចាំធ្វើការបន្សាប និងបំផ្លាញចោលដោយសុវត្ថិភាព និងបច្ចេកទេសវិទ្យាសាស្ត្រ។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

**៤.១.** បន្តសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

**៤.២.** បន្តចុះជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងប្រសិទ្ធភាពការអនុវត្តយន្តការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពគយនិងរដ្ឋាករតាមច្រកទ្វារព្រំដែន។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំដែលបានឯកភាព ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.២.** បន្តសម្របសម្រួល និងសហការជាមួយឡាវ និងវៀតណាម ដើម្បីពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូ ដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.២.** បន្តចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។

**៦.៣.** បន្តសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាល ស្តីពីបច្ចេកទេសស៊ើបអង្កេតជាន់ខ្ពស់ ការគ្រប់គ្រងកន្លែងកើតហេតុ ការឃ្លាំងមើល និងការប្រគល់ទទួលដោយមានការឃ្លាំមើល នៅខេត្តសៀមរាប។

**៦.៤.** ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីកិច្ចសហ-ប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមលម្ហសមុទ្រ រវាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយកងកម្លាំងឆ្មាំសមុទ្រនៃសាធារណៈរដ្ឋកូរ៉េ។

**៦.៥.** ត្រៀមរៀបចំសម្រាប់ព្រឹត្តិការណ៍អមក្នុងសម័យប្រជុំលើកទី៦៩នៃគណៈកម្មការគ្រឿងញៀន (CND) ដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ធ្វើជាម្ចាស់ព្រឹត្តិការណ៍ នៅប្រទេសអូទ្រីស។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**៧.១.** បន្តពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.២.** បន្តពង្រឹងការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**៧.៣.** បន្តការពិនិត្យសម្រេច និងដំណើរការអនុវត្តឯកសារទស្សនទានស្តីពីការអង្កេតអំពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន។

**៧.៤.** ត្រៀមសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងកែសម្រួលសេចក្តីប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់គ្រឿងញៀនដោយខុសច្បាប់។

**៧.៥.** ត្រៀមរៀបចំផ្សព្វផ្សាយពីតួនាទីភារកិច្ចរបស់ផ្នែកចំណុះការិយាល័យ តាមនាយកដ្ឋាន និងមន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣.។

**៧.៦.** ត្រៀមរៀបចំបញ្ចូលសារធាតុញៀន ប៉ះពាល់ប្រព័ន្ធប្រសាទ និងសារធាតុគីមីផ្សំថ្មីៗ ចូលទៅក្នុងឧបសម្ព័ន្ធនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៧.** ត្រៀមរៀបចំការពិនិត្យ និងវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងគ្រឿងញៀន ២០២៤-២០២៨។

**៧.៨.** ត្រៀមរៀបចំបញ្ជូនសេចក្តីព្រាងមេពាក្យ សទ្ទានុក្រមបច្ចេកសព្ទពាក់ព័ន្ធការងារគ្រឿងញៀនជូនគណៈកម្មការរៀបចំសទ្ទានុក្រមបច្ចេកសព្ទ ក្នុងវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៃក្រសួងមហាផ្ទៃ។

**៧.៩.** ត្រៀមរៀបចំរបាយការណ៍ផ្តល់ធាតុចូលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ឆ្នាំ២០២៥ ជូនទីស្តីការគណរដ្ឋមន្ត្រី ដើម្បីដាក់បញ្ចូលនៅក្នុងរបាយការណ៍សកម្មភាពការងាររបស់រាជរដ្ឋាភិបាល។

**៧.១០.** ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ **មាស-វីរិទ្ធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.៣.
  " ដើម្បីគោរពជូនជ្រាប "
- អនុប្រធាន និងសមាជិក អ.ជ.ប.គ.៣.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- អគ្គលេខាធិការរងនៃអ.ជ.ប.គ.៣.
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
- នាយកដ្ឋាននិងមន្ទីរពិសោធន៍នៃ អ.ជ.ប.គ.៣.
  " ដើម្បីមុខការ "
- ឯកសារ កាលប្បវត្តិ